# ស្ថាប័នអប់រំយុវជនខ្មែរ

## (K. C. E. O.)

ស្ថាប័នអប់រំយុវជនខ្មែរមានគោលបំណង ផ្តល់ឲ្យយុវជនមានឱកាសនឹងសិក្សាមុខវិជ្ជាជីវៈផ្សេងៗ ប្រយោជន៍នឹងបង្កើនឱកាសស្វែងរកការសិក្សាឲ្យបានខ្ពស់តទៅទៀត ហើយនិងការងារ។ ស្ថាប័នអប់រំយុវជនខ្មែរខិតខំប្រឹងប្រែងបណ្តុះបណ្តាលកុមារៗព្រមទាំងយុវជន មិនថាមានមិនថាក្រឲ្យបានរៀនមុខវិជ្ជាដូចជា ភាសាអង់គ្លេស គណិត-សាស្ត្រ ភាសាខ្មែរ វិជ្ជាប្រើកុំព្យូទ័រ(computer) សុខាភិបាល និងអនាម័យ។

នៅភូមិអង្គដែលជាភូមិជនបទ ស្ថាប័នអប់រំយុវជនខ្មែរប្តេជ្ញាថានឹងរក្សាទំនាក់ទំនងឲ្យបានជិតស្និទ្ធជាមួយសហគមន៍នៅទីនោះ ព្រមទាំងបណ្តុះបណ្តាលទំនាក់ទំនងឲ្យកាន់តែជ្រាលជ្រៅជាមួយអង្គការផ្សេងទៀត ដែលមានគោលការណ៍ប្រហាក់ប្រហែលគ្នា ឬបំពេញគ្នាទៅវិញទៅមក។

ក្រុមគ្រួសារយុវជនទាំងនោះមានបញ្ហាថវិកា ដោយយល់ឃើញយ៉ាងនេះ ស្ថាប័នអប់រំយុវជនខ្មែរដែលមានលោកហឹម-ម៉ារិននិងបុគ្គលិក ក៏បានបង្កើតកម្មវិធីឧបត្ថម្ភយុវជនឡើង។ គោលបំណងគឺជួយដល់ពួកយុវជននិងក្រុមគ្រួសារ មានលទ្ធភាពរកពេលវេលាឲ្យយុវជនទៅសាលារៀន ហើយនិងជួយស្ថាប័នអប់រំយុវជនខ្មែរក្នុងការគ្រប់គ្រង ដើម្បីឲ្យសាលារៀនមានដំណើរការទៅបាន។ យើងខ្ញុំសូមឲ្យគេជួយវិភាគទាន $120 សំរាប់១២ខែខាងមុខ។ ៥០ភាគ ១០០នៃមូលនិធិនេះសម្រាប់ជួយក្រុមគ្រួសារដោយតម្លើងប្រាក់ចំណូល ក្នុងការចិញ្ចឹមកូនសត្វ បណ្តុះកូនរុក្ខជាតិ។ល។ រួចជាការចាំបាច់ត្រូវទិញទោចក្រយាន(កង់) ដើម្បីដឹកជញ្ជូនទៅមកពីសាលារៀននូវសំលៀកបំពាក់ប្រដាប់ប្រដារផ្សេងៗ។

ចំណែក៥០ភាគ១០០ទៀតនៃមូលនិធិឧបត្ថម្ភ ត្រូវផ្តល់ដល់ស្ថាប័នអប់រំយុវជន

ខ្មែរ សំរាប់បៀវត្សបុគ្គលិក ថ្លៃក្រសួងរដ្ឋាភិបាល ថ្លៃភ្លើងអគ្គិសនី ហើយនិងថ្លៃប្រព័ន្ធ Internet។

ក្រុមគ្រួសារណាដែលមានធនធានក៏ជួយផ្តល់វិភាគទាន សំរាប់ថ្លៃដំណើរការនានា។ តែទោះបីយ៉ាងណា ក៏មានគ្រួសារជាច្រើនដែលមិនអាចមានលទ្ធភាពបង់វិភាគទាន ហើយជាញឹកញាយក៏ឥតមានពេលវេលា ឲ្យកូនរបស់ខ្លួនចាកចេញពីផ្ទះទៅសាលារៀនផង មានតែប្រដាប់ប្រដារសាលារៀននិងប្រាក់ចំណាយខ្លះប៉ុណ្ណោះ។ ត្រូវរំលែកពាក់កណ្តាលនៃមូលនិធិឧបត្ថម្ភ ទៅឲ្យគ្រួសារទាំងនោះដើម្បីឲ្យកូនអាចចូលរៀនបាន។ ស្ថាប័នអប់រំយុវជនខ្មែរក៏ផ្តល់ឱកាសឲ្យមានកម្មវិធី ជួយក្រុមគ្រួសារទាំងអស់នោះបានប្រាក់ចំណូលច្រើនឡើង។

សូមមេត្តាពិនិត្យពិចារណា សន្យាជួយគាំទ្រកូននីមួយៗឬក៏ច្រើន ក្នុងមួយឆ្នាំ$120 ដែលគិតមើលទៅគឺតិចជាងថ្លៃកាហ្វេមួយពែងក្នុងមួយសប្តាហ៍ ឬ$10ក្នុងមួយខែ។ ឯការបង់ប្រាក់អាចបង់ទាំងអស់តែម្តង ឬបង់រំលោះក្នុងមួយឆ្នាំក៏បាន។ គោលបំណងនៃស្ថាប័នអប់រំយុវជនខ្មែរ គឺត្រូវការរកអ្នកឧបត្ថម្ភ១០០នាក់ក្នុងមួយឆ្នាំនារយៈពេលពីរឬបីឆ្នាំខាងមុខ។

រឿងរ៉ាវនិងពត៌មានថ្មីៗចេញពីស្ថាប័នអប់រំយុវជនខ្មែរ ត្រូវចែកចាយដល់អ្នកឧបត្ថម្ភគាំទ្រទាំងឡាយ ប៉ុន្តែសូមកុំផ្ញើមផ្ទួជាមួយនឹងពួកយុវជនជាពិសេស ឬជាមួយនឹងក្រុមគ្រួសារគេ ដើម្បីជាការគោរពដល់ភាពផ្ទាល់ខ្លួន។ ហើយបើសិនណាជាចង់ផ្សព្វផ្សាយ គឺអាចធ្វើបាន ដោយបង្កើតទំនាក់ទំនងជាមួយនឹងសហគមន៍ស្ថាប័នអប់រំយុវជនខ្មែរ តាមការប្រាស្រ័យទាក់ទងគ្នា។

វិភាគទានអាចផ្ញើទៅ(This Link will be ready to be added in a couple of Days)